**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

PHNOM PENH WATER SUPPLY AUTHORITY
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
លេខ ..០១០....ល.ជ.ណ

ថ្ងៃព្រហស្បតិ៍..កើត..ខែ.....ផល្គុន.....ឆ្នាំ ច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី.២៤.ខែ.មីនា..ឆ្នាំ ២០១៩

ឯកសារភ្ជាប់ក្រុមហ៊ុន
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់អំបិលសមុទ្រសម្រាប់ផលិតក្លរ៍ទឹក។

ឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ (រួមទាំងសេចក្តីណែនាំ) មានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានអាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ចាប់ពីថ្ងៃទី១៥ ខែមីនាឆ្នាំ២០១៩ តទៅ រៀងរាល់ម៉ោងធ្វើការ (៨ព្រឹកដល់១៦:៣០ល្ងាច) ដល់ថ្ងៃទី២៣ ខែមេសាឆ្នាំ២០១៩ ត្រឹមវេលាម៉ោង ១៦:០០រសៀល ក្នុងមួយច្បាប់តម្លៃ ៦០០,០០០រៀល។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃគឺ ថ្ងៃទី២៤ ខែមេសាឆ្នាំ២០១៩ វេលាម៉ោង ១៥:១០នាទី។

កាលបរិច្ឆេទបើកសំណើដេញថ្លៃគឺ ថ្ងៃទី២៤ ខែមេសាឆ្នាំ២០១៩ វេលាម៉ោង ១៥:១០នាទី នៅអង្គភាពលទ្ធកម្មរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ជាន់ទី១) អាសយដ្ឋានខាងលើ។

គ្រប់ពាក្យដេញថ្លៃទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវប្រាក់កក់ធានាការដេញថ្លៃដែលមានចំនួនដូចបានកំណត់ក្នុងឯកសារដេញថ្លៃ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ (ទូរស័ព្ទទាក់ទងលេខ ០១៧ ៨១១ ៩១១)។

**អគ្គនាយក**

ស៊ឹម ស៊ីថា

ចម្លងជូន៖
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
  "ដើម្បីជ្រាបជាព័ត៌មាន"
- ឯកសារ-កាលប្បវត្តិ